# ក្បួនហៅព្រះលឹងស្រូវ

អស់លោកចាស់ទុំ ក្រមុំមេម៉ាយ ស្ដាប់ខ្ញុំនិយាយ ដំណើរហៅព្រះលឹងស្រូវ
ឆ្នាំនេះឆ្នាំកោរ[1] ភ្លៀងឱ[2] ដោគដាំ ស្រុកលោកស្រណុក ទុកជាចំណាំ
ផ្ការឃដើមឆ្នាំ ពិសាខភ្លៀងម្ដង អស់ក្មេងៗហើយ អ្នកកុំនៅឡើយ
ត្រូវរៀបនង្គ័លរនាស់ ក្របីគោភ្ជួររាស់ សាបព្រួសដកស្ទូង ឱខ្នងយើងើយ
សឹងតែហាលថ្ងៃ ឱដៃយើងើយ ច្រត់ព្រះធរណី អញ្ជើញនាងទេព
ដំណើបខ្យាយ ព្រះពាយជាគង់ អញ្ជើញនាងអង្គ នាងគង់លំអង់ធ្នង់
អញ្ជើញនាងគង់ ក្រយ៉ាសងើយ អញ្ជើញនាងមកហើយ បំពេញផ្ទះយើង។
នេះហៅម្ដង។

យើងសង់សមៀក យើងដោតព្រះភូមិ នាងលាស់នាងលោម ហាក់ដូចពពាលគ្រាដ
ខ្យល់[3] បក់ពីស្លូកិ ក្លូរនាងឱនល្វៀក ខ្យល់បក់ត្រសៀក នាងអង្អៀកផ្ទៃផ្កា
គ្រាប់នាងនោះណា ដូចមាសនពគុណា ស្រូវយើងនឹងថ្ដោក[4] មួយកញ្ជើមាសធំ
សំពត់សមួយ យើងក្រាសជាអាសន៍ សំពត់សមាសមួយ យើងចងជាផ្ដាន[5]
អញ្ជើញនាងមកសម្រាន បំពេញផ្ទះយើង។
នេះហៅម្ដង។

---

[1] កោរ ~ កុរ

[2] បង្អោរ ~ បង្អុរ

[3] អ្នកស្រុកតំបន់លើហៅ “ខ្យល់” ថា “ខ្យល់” ដូច្នេះ។

[4] ស្រុកខ្លះហៅដោក។

[5] ពិតាន។

យើងសង់ផ្ទះមួយ ក្រែងវាចង្អៀត យើងសង់ផ្ទះមួយទៀត បើកល្វែងឲ្យធំ

សង់យុង[៦] ធាន៩ ព្រះភូមិទាំងបី លោកតែងនៅចាំ បរយ៉ាបទាំង៩

តែងនាំនាងឡើង តាំងយូក្រអែ ជន្លែនាងឡើង អញ្ជើញនាងមក

ពីស្រុកគាលោក[៧] អញ្ជើញនាងមក ពីស្រុកចាក្នុំទ្រនំសេក អញ្ជើញនាងមកដេក

បំពេញផ្ទះយើង។

នេះហៅម្ដង។

អញ្ជើញពីរូងពីរាម ពីពាមធន្លេ ពីកោះរំពេ ពីទុងចង្ក្រ

ពីថ្មអណ្ដែត ពីកោះស្វាកេតុ[៨] ពីលើយល់នាយ នាងហូរដូចទ

នាងហូរដូចទឹក តាំកល់យប់ព្រឹក គ្រប់រាត្រីហោង បើកទ្វារឃកើត

ដើងជាន់ចំអើត ថានាងមកហើយ យើងរៀបចាយនាង រៀបនឹងត្រីស្វាត

ឲ្យនាងសង្វាត នាងឲ្យពរយើង រៀបទាំងនំទៀប រៀបទាំងនំគម

រៀបទាំងនំអន្សមឱប រៀបទាំងអន្សមត្រល់ រៀបទាំងអន្សមក្បុង ចងចាច់សំយ៉ុង

ដាក់ដោយហាមស្តក ឡើងមកប្រញ៉ាយ ខ្ញុំឃងនឹងថ្វាយ ក្រយ៉ានាងហោង

ខ្ញុំសូមឲ្យកើត ខ្ញុំសូមឲ្យធាន ខ្ញុំសូមឲ្យមាន ឥតគេស្មើឡើយ

ឆ្នាំនេះយើងប៉ុណ្ណោះ ចាំមើលឆ្នាំក្អែកអេះ ធានវែកដំបូកចាក់ យើងទិញគោប្រលេង[៩]

យើងនឹងបរលេង មានគោរទេះ មានសេះដីរ មានទាំងខ្ញុំប្រុស

មានទាំងខ្ញុំស្រី ខ្ញុំប្រុសគេវាយ ខ្ញុំស្រីគេខ្វាំង លោះទាំងខ្ញុំប្រុស

គ្រាន់ចោះរបង ខ្ញុំស្រីសោតហោង គ្រាន់វាចោសសម្រាម កុំអាងវាជាខ្ញុំ

ប្រចាំនឹងវាពេក ក្រែងថ្ងៃណោះវារអែង ក្រែងស្អែកវាខ្ជិល ច្បាប់ចាស់មួយណា

---

[៦] យុង គឺជង្រុក។

[៧] សួគ៌ាលោក?

[៨] អានថា “ស្វាកែត”។

[៩] ប្រឡឹង?

វាមកជាខ្ញុំ ទុកស្មើខ្លាក់ក្អែក សងខាងនេហោង កូនមួយសោតហោង
ទុកស្មើខ្លាក់ក្អែក មួយខាងនេហោង។ នាងក្រោកពីព្រឹក ដាស់កូនដាស់ចៅ
ដាស់ខ្ញុំកំដរ នាងដើរទៅចម្ការស្រែ នាងដើរហែ។ទៅចម្ការ ថ្ងៃល្ងាចសូរិយា
នាំគ្នាមកផ្ទះ អស់លោកស្រូវអើយ លោកកុំកំចាំង ដោយដើងកញ្ជ្រាំង
ក្រែងដីវាចោច ក្រែងស្រម៉ោចវាពាំ មាត់សេកកំពក មាត់រលកកំប៉ុយ
មាត់ចាបក្រនេន មាត់ជ្រិកកង់ហែង មាត់រមាំងកញ្ជ្រើង មាត់ប្រើសក្រញេស
មាត់ទន្សាយកប៉េស មាត់ក្ដាមរាមទាម ដែលក្របីវាជីះជាន់ ដែលមាន់កកាយ
ទន្សាយកាត់ អញ្ជើញនាងមកពីមាត់សត្វ មកនៅនឹងផ្ទះយើងហោង។
ខែចេត្រពិសាខពេកពន់ រណ្ដាប់តូជធារ ដាក់ការុងដាក់ជាល ដោយពណ៌ាទីនៃ
សាច់ញាតិបុលខ្ញី រង្វាល់មានស្រាប់ហោង។
ស្រេចហើយ គោះគងបីដង តាំងហ៊ោយកង់យ ព្រះលីងស្រូវយើង្វើយ។នេះចប់មួយមេហើយ។
នេះត្រូវឲ្យក្មេងស្រីជំនង់រៀនហៅឈ្មោះស្រូវ។

មកអើយមកណា ព្រះលីងលោកព្រះមេណាមក អញ្ជើនាងនេព ដំណើបខ្សាយ
ដំណើបក្អុក ដំណើបខ្ញី ដំណើបខោង ដំណើបស្វាបស្បៃ ដំណើបដំបូក
ដំណើបលូត នាងស្អាតកំដោក ស្រូវច្រេះកំភ្ញេញ នាងឱកភ្ជាព្រំ នាងក្រអូប
ដំណើបកៀត ស្នៀតសក់ ដំណើបប្រម៉ា ស្រូវមេមង់ ដំណើបខ្មៅ ស្រូវស្រៀវ
ដំណើបឃ្វោក កូនត្រី ដំណើបកន្ទួត ស្រូវព្រួតក្រាប់ត្រប់ ដំណើបអង្សាង បណ្ដូលក្អុក
ដំណើបខោង កូនឃ្មុំ ដំណើបផ្កាស្វា ស្រូវកើកុកសរ ក្រចកស្វាយ មហាកំពាន
នាងងើយកូនស្ដេច ស្រូវផ្កាអំពិល អញ្ជើញនាងក្វាយ ព្រះពាយជាកង
អញ្ជើញនាងកុក អញ្ជើញនាងកង អង្គ្រងលំអងខ្សាច់ វិតលំអងធ្នង
នាងកងខ្សែ នាងមកពីស្រែ នាង្វើយកល់ព្រែច នាងចេកផ្កាដូង ស្រូវខោងផ្កាស្វា
ស្រលិតនាងឆ្មារ ផ្កាកុម្ពក្នុំយោង ខោងស្មោង កេនទងសន្ដែ អង្ករសំបុកក្រឹម
កូនដោកក្រចកជ្រូក ក្រចកចាប ក្រចកជាស ផ្កាក្រចាស ផ្កាពពេល

រិតក្រិយ៉ាសង្វើយ អញ្ជើញនាងមកដល់ហើយ អញ្ជើញនាងមកពីមាត់សេកមាត់សត្វ មាត់គោ មាត់ក្របី មាត់ដំរី មាត់សេះ មាត់មាន់មាត់ទា មាត់ឆ្កែមាត់ឆ្មា មាត់ស្រម៉ោច មាត់សង្ហារ មាន់ទោមាន់ទឹក ប្រវឹកលលក អញ្ជើញនាងមកពីចម្ការ នាងមកពីស្រែ នាងដើរហៃហៃ នាងមកដល់ហើយ បំពេញផ្ទះយើង។ មាត់សេកក្រហាប មាត់ចាបក្រហួច មាត់ទោចកុងបុង ក្ងោកចោ៉យចុង ចូលយុងយើងវិញណាមក។
នេះចប់មេស្រូវហើយ។

បើនឹងធ្វើកិច្ចហៅព្រះលឹងស្រូវនោះ ធ្វើដូចរានពុទ្ធគុណ៣ថ្នាក់។ ថ្នាក់ក្រោមក្តារ១០ហត្ថ, ម្ខាង២សន្ទឹក, ជុំវិញថ្នាក់កណ្តាល៨ហត្ថ, ម្ខាង២សន្ទឹកដូចគ្នាជុំវិញ, ថ្នាក់លើក្តារ៦ហត្ថ, ៤ជ្រុងដូចគ្នា។ ទាំងអស់អ្នកសូត្រមាន៣នាក់, ប្រុសៗព្រហ្មចារីស្រីៗមាន២នាក់។ ហើយចងពិតានពីលើតុបតែង គឺទំអន្ទ្រម, ត្រីស្លាតមាន៨, កុំឲ្យអត់សសរ, រានថ្នាក់ខាងកើតត្រូវដាក់បាយស្រី២ដើម, មួយដើម៥រួត។ ពូជស្រូវដាក់កណ្តាលអ្នកសូត្រអ្នកហៅ។ថ្នាក់ក្រោម, ថ្នាក់កណ្តាលពូជស្រូវគ្រប់ឈ្មោះដាក់ជាលដាក់កញ្ជើ គ្រប់ផ្ទះចុះឈ្មោះនឹងកញ្ចប់គ្រប់គ្នា មានគីរីយាល់[១០] ដើរហៅដាក់ពូជគ្រប់ផ្ទះ។ ទៅវិញមានអំបោះដៃចងដៃអ្នកដើរហៅគ្រប់ផ្ទះកុំខាន ថាព្រះលឹងស្រូវយើងមកវិញហើយ។ កាន់គងចាកហោិវាយផងគ្រប់មុខធ្លាផ្ទះ។ អ្នកហៅត្រូវហៅពីក្រៅ១៩ បញ្ចូលទៅក្នុងដាក់ការុងទៅវិញទៅ។

១០ ?